# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៧...សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងតំណាងជាតិសំរាប់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញធម្មនុញ្ញ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ច បន្ថែមលើមុខងារបច្ចុប្បន្ន ជូនឥស្សរជន ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាតំណាងជាតិ សំរាប់ក្រុមប្រឹក្សាសហគមន៏នយោបាយ-សន្តិសុខអាស៊ាន និងឯកឧត្តម **កៅ គីមហួន** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអ្នកជំនួសក្នុងករណីអវត្តមាន ឯកឧត្តម តំណាងជាតិ ។

២-ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាតំណាងជាតិ សំរាប់ក្រុមប្រឹក្សាសហគមន៏សេដ្ឋកិច្ចអាស៊ាន និងឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកជំនួស ក្នុងករណី អវត្តមាន ឯកឧត្តម តំណាងជាតិ ។

www.pheakdeylaw.com

៣-ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាតំណាងជាតិ សំរាប់ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន និងឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកជំនួស ក្នុងករណីអវត្តមាន ឯកឧត្តម តំណាងជាតិ ។

**ប្រការ ២** : តំណាងជាតិ នៃក្រុមប្រឹក្សាសហគមន៍ទាំងបីខាងលើ មានសិទ្ធិអញ្ជើញតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ ក្រោមឱវាទនៅក្នុងសហគមន៍នីមួយៗមកចូលរួមប្រជុំ ដើម្បីសម្របសម្រួលការងារ របស់ក្រុមប្រឹក្សានោះ ។

**ប្រការ ៣** : តំណាងជាតិ នៃក្រុមប្រឹក្សាសហគមន៍ទាំងបីខាងលើ អាចអញ្ជើញក្រសួង ឬស្ថាប័នពាក់ព័ន្ធ ក្រោមឱវាទនៅក្នុងសហគមន៍នីមួយៗទៅចូលរួមប្រជុំក្រុមប្រឹក្សាសហគមន៍អាស៊ាន ក្នុងករណីចាំបាច់ ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ និងប្រធាន គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១ និង៥
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com